**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខៈ ១៣៧ ប្រក.កសក

# ប្រកាស

**ស្តីពី**

**ការលុបចោលរោងចក្រអារ-កែច្នៃឈើ ជាសាខា**

**របស់ក្រុមហ៊ុនព្រៃសម្បទានក្នុងទូទាំងប្រទេស**

**រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខាប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញសេចក្តីប្រកាសលេខ ៥៧២១ កសក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្តីពីការផ្អាកសកម្មភាពអាជីវកម្មព្រៃគុបសម្រាប់ក្រុមហ៊ុនព្រៃសម្បទាន
- បានឃើញសេចក្តីប្រកាសលេខ ១៥៥ ប្រក.កសក ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្តីពីការផ្អាកសកម្មភាពដឹកជញ្ជូនឈើហ៊ុបមូលរបស់ក្រុមហ៊ុនព្រៃសម្បទាន
- តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

**ប្រការ១ៈ** លុបចោលរាល់ប្រកាសអនុញ្ញាតឱ្យបង្កើតរោងចក្រអារ-កែច្នៃឈើជាសាខារបស់ក្រុមហ៊ុនព្រៃសម្បទាន ក្នុងទូទាំងប្រទេស ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទបានអនុញ្ញាតកន្លងមក ។

**ប្រការ២:** រោងចក្រអារ-កែច្នៃឈើជាសាខារបស់ក្រុមហ៊ុនព្រៃសម្បទានទាំងអស់ ត្រូវបញ្ឈប់សកម្មភាពអាជីវកម្ម និង ធ្វើការរុះរើសំភារៈបរិក្ខារទាំងអស់ពីក្នុងរោងចក្រត្រឹមដំណាច់ខែ មេសា ឆ្នាំ ២០០៦ ជាកំហិត ។

**ប្រការ៣:** រដ្ឋបាលព្រៃឈើ ត្រូវតាមដាន ត្រួតពិនិត្យ និង ទប់ស្កាត់គ្រប់សកម្មភាពរោងចក្រអារ-កែច្នៃឈើដែលត្រូវលុបចោលទាំងអស់ និង រោងចក្រដែលគ្មានច្បាប់អនុញ្ញាត ។

**ប្រការ៤:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការ និង ស្ថិតិ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានមន្ទីរកសិកម្មខេត្ត-ក្រុង និង ក្រុមហ៊ុនព្រៃសម្បទានទាំងអស់ ត្រូវទទួលបន្ទុកតាមភារៈកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ៤ ឆ្នាំ ២០០៦

ច័ន្ទ-សារុន

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងផែនការ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់
- សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"
- ដូចប្រការ៥

"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ